# I - ទីស្តីការគណៈរដ្ឋមន្ត្រី

## អនុក្រឹត្យ

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៤

## អនុក្រឹត្យលេខ ២៤ អនក្រ.ពមា

## ស្តីពីការផ្ទេរសាលាមធ្យមសិក្សាឯកទេសពាណិជ្ជកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សំរេច

**មាត្រា ១** : ផ្ទេរសាលាមធ្យមសិក្សាឯកទេសពាណិជ្ជកម្ម របស់ក្រសួងពាណិជ្ជកម្ម ព្រមទាំងចលនវត្ថុ និង អចលនវត្ថុទាំងអស់ អោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ២** : ចំពោះការផ្ទេរក្របខ័ណ្ឌមន្ត្រី រាជការរបស់សាលានេះ ក្រសួងពាណិជ្ជកម្ម និង ក្រសួងអប់រំយុវជន និង កីឡា ត្រូវពិភាក្សាគ្នាតាមសភាពជាក់ស្តែង ។

**មាត្រា ៣** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា និង ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
|---|---|
| ព្រះហស្តលេខានិងត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |